01642983

E004/2/1.2.25

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៤/២/០៧-០៩-២០០៩-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 13 / 02 / 2020
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អជសដ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើការបំភ្លឺអំពីសារអេឡិចត្រូនិករបស់ អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (អមដោយឧបសម្ព័ន្ធសាធារណៈ ក-ច)**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J. Hollis
សហព្រះរាជអាជ្ញាអន្តរជាតិ

**ចម្លងជូន:**
លោកស្រី ជា លាង
សហព្រះរាជអាជ្ញាជាតិ

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Claudia FENZ
ចៅក្រម យ៉ា សុខន
ចៅក្រម Martin KAROPKIN
ចៅក្រម យូរ ឧត្តារ៉ា

**សហមេធាវី សោ អាន**
លោក មុំ លុជ្ស
លោក Richard ROGERS
លោក Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

## I. សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") ស្នើសុំការបំភ្លឺអំពីសារអេឡិចត្រូនិក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អង្គជំនុំជម្រះសាលាដំបូង តបទៅនឹងសំណើរបស់ ស.ព.អ ទាក់ទងនឹងសេចក្តីជូនដំណឹង និងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃរឿងក្តី០០៤/២ និងសំណុំរឿងដែលនៅសេសសល់។ សារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូងថ្លែងថា *"អង្គជំនុំជំម្រះសាលាដំបូង* នៅតែមិនទាន់ទទួលបានការជូនដំណឹង*ជាផ្លូវការ* អំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះនៅឡើយ។ សំណុំរឿងមិនទាន់ត្រូវបានបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងនៅឡើយ។ វាអាស្រ័យលើអង្គបុរេជំនុំជម្រះក្នុងការចាប់ផ្តើមវិធានការទាំងពីរនេះ"[1]។ ស.ព.អ ស្នើសុំការបំភ្លឺអំពីអត្ថន័យ និងសារសំខាន់នៃភាសាដែលត្រូវបានប្រើនៅក្នុងសារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូង។

2. ជាងនេះទៀត ស.ព.អ ស្នើសុំថា សំណើសុំការបំភ្លឺនេះ និងការដាក់ឯកសារនានាផ្សេងទៀតរបស់គាត់ទៅកាន់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០៤/២ ត្រូវដាក់ឲ្យមានជាសាធារណៈ តាមរយៈការដាក់លេខឯកសារសំណុំរឿង និងការជូនដំណឹងតាមក្រោយ ឬជាជម្រើសម្យ៉ាងទៀត ដាក់នៅលើគេហទំព័ររបស់ អ.វ.ត.ក ដើម្បីធានាដល់តម្លាភាពនៃកិច្ចដំណើរការនីតិវិធី។

## II. ប្រវត្តិនីតិវិធី

3. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អ.ប.ជ បានជូនដំណឹងអំពីសេចក្តីពិចារណាជាសាធារណៈរបស់ខ្លួនក្នុងសំណុំរឿងនេះ។ អ.ប.ជ ខកខានមិនបានឈានទៅដល់សេចក្តីសម្រេចមួយដែលមានសំឡេងភាគច្រើនលើសលុប (សំឡេងគាំទ្រពីចៅក្រមយ៉ាងហោចណាស់បួនរូបក្នុងចំណោមចៅក្រមប្រាំរូប) ដែលតម្រូវ ដើម្បីបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះជាសាធារណៈនេះ។ បញ្ជី

[1] សារអេឡិចត្រូនិកមានចំណងជើងថា "ពាក់ព័ន្ធនឹងសំណើចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០" ដែលបានផ្ញើដោយក្រឡាបញ្ជី និងមន្ត្រីច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង លឹម ស៊ុយហុង តាងនាមឲ្យអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ១១:៤៤ព្រឹក ទៅកាន់សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តី អោ អាន ដែលបានចម្លងជូនចៅក្រមនៃអង្គបុរេជំនុំជម្រះ ក៏ដូចជាប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ("សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០")។ ភ្ជាប់ជាឧបសម្ពន្ធ ក។

អ្នកទទួលឯកសារនៃសេចក្តីជូនដំណឹងអំពីសេចក្តីពិចារណានេះ រួមបញ្ចូលក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង[2]។

4. នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្របតាមវិធាន ៣៩(៤), ៧៧(១៣)(ខ), ៨០(១) និង ៧៩ នៃវិធានផ្ទៃក្នុង[3] ស.ព.អ បានដាក់សំណើមួយជាសំណៅរឹងទៅកាន់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំការពន្យារពេលដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន និងបានស្នើសុំឱ្យមានកិច្ចប្រជុំរៀបចំសវនាការ[4]។ ស.ព.អ ដឹងថា ការដាក់ឯកសារនេះត្រូវបានបញ្ជូនទៅកាន់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង។

5. នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ស.ព.អ បានទទួលសំណើរបស់ អោ អាន ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ខ្លួនមិនត្រូវបានប្ដឹងឱ្យទទួលយករឿងក្តី ០០៤/២ ដោយត្រឹមត្រូវតាមច្បាប់នោះទេ ឬជាជម្រើសម្យ៉ាងទៀតថា អង្គជំនុំជម្រះសាលាដំបូងផ្តល់ការណែនាំអំពីការដាក់អញ្ញត្រកម្ម និងអនុញ្ញាតផ្តល់ឱ្យ អោ អាន នូវពេលវេលាគ្រប់គ្រាន់ (យ៉ាងហោចណាស់ ៦០ថ្ងៃ) ដើម្បីដាក់ការជំទាស់របស់គាត់[5]។ ស.ព.អ បានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរនេះជាសំណៅរឹង

---

[2] សំណុំរឿង០០៤/២ ឯកសារ **D359/24** & **D360/33** សេចក្តីពិចារណារបស់លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ (“សេចក្តីពិចារណា”)។ *សូមមើល* សេចក្តីជូនដំណឹងតាមសារអេឡិចត្រូនិកពីមន្ត្រីទទួលបន្ទុកសំណុំរឿង ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៤:៥៣ល្ងាច ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ខ។ បញ្ជីអ្នកទទួលឯកសារក៏រួមបញ្ចូលឈ្មោះចៅក្រមអង្គជំនុំជម្រះសាលាដំបូងពីររូបផងដែរ គឺចៅក្រម Claudia Fenz និងចៅក្រម Martin Karopkin។

[3] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មទី៩) ដូចដែលត្រូវបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ (“វិធានផ្ទៃក្នុង ឬ “វិធាន”)។

[4] *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំពន្យារពេលវេលាតាមវិធាន ៨០ នៃវិធានវិធានផ្ទៃក្នុង និងសុំបើកកិច្ចប្រជុំរៀបចំសវនាការ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ (“សំណើរបស់ ស.ព.អ សុំបើកកិច្ចប្រជុំរៀបចំសវនាការ”) ដែលត្រូវបានបញ្ជូនជាសំណៅរឹងទៅកាន់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង។ *សូមមើលផងដែរ* សារអេឡិចត្រូនិកមានចំណងជើងថា “សេចក្តីជូនដំណឹង” បញ្ជូនដោយ លឹម ស៊ុយហុង ក្នុងនាមជាអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ១:៤៨ ល្ងាច (“សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០”) ដោយបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានា ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ភ្ជាប់ជាឧបសម្ព័ន្ធ គ។

[5] *សូមមើល*សារអេឡិចត្រូនិកផ្ញើទៅកាន់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ពី Göran Sluiter នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ វេលាម៉ោង ៣:៣៣ ល្ងាច។ សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តីផ្សេងទៀតត្រូវបានចម្លងជូន តែដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានចម្លងជូនទេ។ ភ្ជាប់ទៅនឹងសារអេឡិចត្រូនិកនោះគឺជាលិខិតចេញពីសហមេធាវីការពារក្តីផ្ញើទៅកាន់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។ *សូមមើលផងដែរ* សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២០[6]។ ស.ព.អ ដឹងថា ការដាក់ឯកសារនេះត្រូវបានបញ្ជូនទៅកាន់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង។

6. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ដោយមិនបានទទួលការបង្គាប់ណាមួយពីអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងសំណើសុំពន្យារពេលដាក់បញ្ជីរបស់ខ្លួន ស.ព.អ បានដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ខ្លួន អនុលោមតាមវិធាន ៨០(១) នៃវិធានផ្ទៃក្នុង ជាសំណៅរឹង ស្របតាមកាលបរិច្ឆេទនៃសំណើសុំពន្យារពេល[7]។ ស.ព.អ ដឹងថា ការដាក់ឯកសារនេះត្រូវបានបញ្ជូនទៅកាន់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង។

7. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ ស.ព.អ បានទទួលតាមរយៈសារអេឡិចត្រូនិកនូវសារណាមួយពីសហមេធាវីរបស់ អោ អាន ដែលមានចំណងជើងថា "សេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ អោ អាន តាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង"[8]។

8. នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង បានផ្ញើសារអេឡិចត្រូនិកមួយ តាងនាមឲ្យអង្គជំនុំជម្រះសាលាដំបូងថា៖

> អង្គជំនុំជម្រះសាលាដំបូង បានដឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដែលបានផ្សព្វផ្សាយជាសាធារណៈនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ រួមទាំងឯកសារនានា ដែលភាគីបានបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងកន្លងមក។ ប៉ុន្តែរហូតមកដល់ពេលនេះ អង្គជំនុំជម្រះសាលាដំបូង

---

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ អោ អាន ទាក់ទងនឹងការទទួលសំណុំរឿង០០៤/២ ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២០។ *សូមមើលផងដែរ* សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដែលបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានា ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

[7] សារណាបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិតាមវិធាន ៨០ អមដោយឧបសម្ព័ន្ធសម្ងាត់ ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។ *សូមមើលផងដែរ* សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដែលបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានា ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

[8] *សូមមើល* សារអេឡិចត្រូនិកផ្ញើទៅកាន់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ពី Kristin Rosella នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៥.០៩ល្ងាច។ អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា និងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចម្លងជូន។ *សូមមើលផងដែរ* សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ដែលបានបញ្ជាក់ថាបានទទួលឯកសារដែលបានបញ្ជូនដោយភាគីនានាទៅកាន់អង្គជំនុំជម្រះសាលាដំបូង។

មិនបានទទួលសេចក្ដីពិចារណា និងដីកាបញ្ជូនរឿងទៅជំនុំជម្រះព្រមទាំងសំណុំរឿងនៅឡើយទេ[9]។

9. នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ស.ព.អ បានដាក់សំណើជាសំណៅរឹង សុំឱ្យអង្គជំនុំជម្រះសាលាដំបូងស្នើសុំឱ្យអង្គបុរេជំនុំជម្រះចាត់វាល់វិធានការរដ្ឋបាលចាំបាច់ ដើម្បីផ្ដល់ឱ្យមានការបញ្ជូនភ្លាមៗនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងដែលនៅសេសសល់ក្នុងរឿងក្ដី ០០៤/២[10]។ ស.ព.អ ដឹងថា ការដាក់ឯកសារនេះត្រូវបានបញ្ជូនទៅកាន់ក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង។

10. បន្ថែមលើការទទួលរបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង នូវសំណៅរឹងនៃការដាក់ឯកសាររបស់ ស.ព.អ សហព្រះរាជអាជ្ញាអន្តរជាតិ ក៏បានចម្លងជូននូវរាល់ការដាក់ឯកសារនីមួយៗរបស់ខ្លួនទៅកាន់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង សហមេធាវីការពារក្ដី អោ អាន និង មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ[11]។ ការអនុវត្តបែបនេះគឺជាចាំបាច់ដោយយោងទៅលើកង្វះនៃការកំណត់លេខឯកសារជាបន្តបន្ទាប់នៃសំណុំរឿងនេះ សម្រាប់សារណានានានៅចំពោះមុខ

---

[9] សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។ សារអេឡិចត្រូនិកនេះត្រូវបានផ្ញើទៅកាន់សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្ដី អោ អាន ចៅក្រមនៃអង្គបុរេជំនុំជម្រះ និងប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល។

[10] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យអង្គជំនុំជម្រះសាលាដំបូងចាត់វិធានការ ដើម្បីទទួលបានលទ្ធភាពចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០៤/២ (អោ អាន) ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០។ *សូមមើលផងដែរ* សារអេឡិចត្រូនិករបស់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ដោយបានបញ្ជាក់ថាបានទទួលសំណើរបស់ ស.ព.អ។ សំណើនេះត្រូវបានធ្វើឡើងប្រសិនបើវិធានការបន្ថែមទៀតត្រូវបានជឿជាក់ថាចាំបាច់ ដើម្បីឱ្យអង្គជំនុំជម្រះសាលាដំបូងអាចចូលពិនិត្យមើលដីកាបញ្ជូនរឿងទៅជំនុំជម្រះជាសាធារណៈ និងប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាថាតម្រូវឱ្យមានការបញ្ជូនតាមបែបរដ្ឋបាលបែបនេះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះជាសាធារណៈនេះ។

[11] *សូមមើល* សារអេឡិចត្រូនិកក្រោមចំណងជើងថា "ដាក់ចំពោះសំណុំរឿង០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ សំណើសុំពន្យារពេល និង កិច្ចប្រជុំរៀបចំសវនាការ" ផ្ញើចេញដោយ ស.ព.អ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ នៅម៉ោង ៣:៣៦ នាទីរសៀល។ សារអេឡិចត្រូនិកក្រោមចំណងជើងថា "ចម្លើយតបរបស់ ស.ព.អ ទៅនឹងលិខិតរបស់ អោ អាន ស្ដីពីការទទួលយកសំណុំរឿងដោយអង្គជំនុំជម្រះសាលាដំបូង" ផ្ញើចេញដោយ ស.ព.អ នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០២០ នៅម៉ោង ៣:៥៦ នាទីរសៀល។ សារអេឡិចត្រូនិកក្រោមចំណងជើងថា "សំណៅចម្លងនៃសារណារបស់ ស.ព.អ តាមវិធាន៨០(១) នៃវិធានផ្ទៃក្នុង" ផ្ញើចេញដោយ ស.ព.អ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ នៅម៉ោង ២:២៥ នាទីរសៀល។ សារអេឡិចត្រូនិកក្រោមចំណងជើងថា "សំណៅចម្លងនៃសំណើរបស់ ស.ព.អ ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបំពេញកិច្ចដើម្បីឱ្យបានចូលមើល ដីកាសម្រេចបញ្ជូន(អោ អាន)ទៅជំនុំជម្រះក្នុងសំណុំរឿង០០៤/២ និង សំណុំរឿង" ផ្ញើចេញដោយ ស.ព.អ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ នៅម៉ោង ៣:៣៩ នាទីរសៀល។ សារអេឡិចត្រូនិកទាំងនេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ ឃ។

អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០៤/២ ដែលរារាំងដល់ការជូនដំណឹងជាផ្លូវការនៃការដាក់ឯកសារណាមួយ។

11. នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ អង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបទៅនឹងសំណើចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ របស់ ស.ព.អ តាមរយៈសារអេឡិចត្រូនិកពីក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង ផ្ញើមកសហព្រះរាជអាជ្ញា និង សហមេធាវីការពារក្តី អោ អាន ដោយបានចម្លងជូនចៅក្រមនៃអង្គបុរេជំនុំជម្រះ ក៏ដូចជាប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលផងដែរ[12]។

## III. ច្បាប់ជាធរមាន

12. វិធាន១(២) នៃវិធានផ្ទៃក្នុងចែងថា៖

> ជាពិសេស លើកលែងតែមានចែងផ្សេងពីនេះ ការយោងនៅក្នុងវិធានផ្ទៃក្នុងនេះ ចំពោះពាក្យសហចៅក្រមស៊ើបអង្កេត សំដៅទៅដល់សហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលធ្វើការសម្រេចចិត្តរួមគ្នា និងសហចៅក្រមស៊ើបអង្កេតណាម្នាក់ក្នុងចំណោមអ្នក ទាំងពីរ ទោះបីដោយផ្ទាល់ ឬតាមរយៈតំណាង។

13. វិធាន ២១(១) នៃវិធានផ្ទៃក្នុងចែងថា៖

> ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បី**ធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព** ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង [...][13]។

14. វិធាន ៧៧(១៣) ចែងថា៖

> សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម៤(បួន)រូបយ៉ាងតិច ។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា។ ប្រសិនបើសម្លេង

[12] សារអេឡិចត្រូនិកពីក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

[13] គូសបញ្ជាក់បន្ថែម។

ភាគច្រើនដែលតម្រូវមិនអាចរកបានទេ **សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្រ**របស់អង្គបុរេជំនុំជម្រះ**ត្រូវ**អនុវត្តដូចខាងក្រោម៖ [...]

ខ-ក្នុងករណី បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត **ប្រសិនបើមិនអាចរកសម្លេងភាគច្រើនដែលតម្រូវបាននោះទេ អង្គបុរេជំនុំជម្រះ ត្រូវសម្រេចប្តឹងទៅអង្គជំនុំជម្រះសាលាដំបូង ដោយឈរលើមូលដ្ឋានដីកាដំណោះស្រាយ**របស់សហចៅក្រមស៊ើបអង្កេត[14]។

15. វិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងចែងថា៖

សេចក្តីសម្រេចទាំងអស់ស្ថិតនៅក្នុងវិធាននេះ រួមទាំងគំនិតជំទាស់ផងត្រូវមានសំអាងហេតុ និងចុះហត្ថលេខាដោយចៅក្រមទាំងនោះ។ សេចក្តីសម្រេចនេះត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង ភាគីដទៃទៀតដោយក្រឡាបញ្ជីរបស់អង្គបុរេជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតត្រូវបន្តកិច្ចនីតិវិធីជាបន្ទាន់ស្របតាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ។

16. វិធាន ៧៩(១) នៃវិធានផ្ទៃក្នុងចែងថា៖

អង្គជំនុំជម្រះសាលាដំបូង**ទទួលបណ្តឹង** ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬ តាមសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ[15]។

17. កថាខណ្ឌ ៦៨៧ នៃសេចក្តីពិចារណាលើកឡើងថា៖

ដោយផ្អែកទៅលើពាក្យពេចន៍ច្បាស់លាស់នៃវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុងការដែលអង្គបុរេជំនុំជម្រះមិនអាចឈានទៅដល់សេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលប់ ដោយចៅក្រមយ៉ាងតិចបួនរូបនោះ មិនបានរារាំងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ រួមជាមួយនឹងសំណុំរឿង មិនឲ្យបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូងដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចចាប់ផ្តើមកិច្ចដំណើរការនីតិវិធីជំនុំជម្រះប្រឆាំងនឹង អោ អាន។ ស្របជាមួយបទប្បញ្ញត្តិនេះ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះនឹងបញ្ជូនដីកាសម្រេចនេះ រួមជាមួយដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំ

[14] គូសបញ្ជាក់បន្ថែម។

[15] គូសបញ្ជាក់បន្ថែម។

ជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនិងសំណុំរឿងដែលនៅសេសសល់ទៅអង្គជំនុំជម្រះសាលាដំបូង។

18. មាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក[16] ចែងថា៖

អង្គជំនុំជម្រះវិសាមញ្ញ ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជា គឺជាភាគីហត្ថលេខីដែរ។ ក្នុងផលប្រយោជន៍ធានាឱ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងទុកចិត្តបាន ត្រូវយល់ថាតំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្តាញពត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់។ ការលើកលែងមិនឱ្យចូលរួមស្តាប់ការជំនុំជម្រះក្តីនេះ តាមមាត្រា១៤ នៃអនុសញ្ញាអាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែនៅពេលណា ដែលការផ្សព្វផ្សាយចេញទៅនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។

19. មាត្រា ២(១) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ ចែងថា៖

ការដាក់ឯកសារនៅ អ.វ.ត.ក និងការទំនាក់ទំនងទៅវិញទៅមកជាមួយបុគ្គលដែលមានសិទ្ធិដាក់ឯកសារ ត្រូវធ្វើដោយផ្ទាល់ជាមួយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ទៅតាមករណីសមស្រប (ដែលបន្ទាប់ពីនេះហៅកាត់ថា ក្រឡាបញ្ជីដែលពាក់ព័ន្ធ) តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង[17]។

[16] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ (“កិច្ចព្រមព្រៀង អ.វ.ត.ក”)។

[17] គូសបញ្ជាក់បន្ថែម។

## IV. សារណា

20. សារអេឡិចត្រូនិកចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ របស់អង្គជំនុំជម្រះសាលាដំបូង លើកឡើងបញ្ហាចំនួនពីរ ដែល ស.ព.អ ស្នើសុំការបំភ្លឺពាក់ព័ន្ធនឹង (i) ការជូនដំណឹងអំពីសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ និង (ii) ការបញ្ជូនសំណុំរឿងនៃរឿងក្ដី ០០៤/២ ពីអង្គបុរេជំនុំជម្រះ ទៅកាន់អង្គជំនុំជម្រះសាលាដំបូង។ បន្ថែមលើនេះ ស.ព.អ លើកឡើងដោយគោរពថា ការរីកចម្រើនជាបន្តបន្ទាប់នៃរឿងក្ដីនេះតាមរយៈការប្រាស្រ័យទាក់ទងក្រៅផ្លូវការ ដែលសាធារណជនមិនអាចដឹង លើកឡើងនូវបញ្ហាសំខាន់មួយអំពីតម្លាភាពនៃកិច្ចដំណើរការនីតិវិធី។

### ក. ការជូនដំណឹងអំពីសេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ

21. ស.ព.អ កត់សម្គាល់ថា នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាបង្គាប់មួយឲ្យដាក់សម្ភារដើម្បីរៀបចំសវនាការ នៅក្នុងសំណុំរឿង០០២[18]។ នៅក្នុងដីកាបង្គាប់នោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួនបានទទួលសំណុំរឿងនោះ ចាប់តាំងពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ជាកាលបរិច្ឆេទដែលសាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នានាប្រឆាំងនឹងដីកាដំណោះស្រាយសំណុំរឿង០០២ ត្រូវបានជូនដំណឹងតាមរយៈមន្ត្រីទទួលបន្ទុកសំណុំរឿង។ សេចក្ដីជូនដំណឹងជាផ្លូវការតាមសារអេឡិចត្រូនិកនីមួយៗទាំងនេះ មានបញ្ចូលទាំងក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងនៅក្នុងបញ្ជីរាយនាមអ្នកទទួលផងដែរ តែមិនមានចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងនោះទេ[19]។

---

[18] សំណុំរឿង០០២-ឯកសារ **E9** ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១។

[19] បញ្ជីជូនដំណឹងស្ដីពី៖ សំណុំរឿង០០២-ឯកសារ **D427/1/26** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នៅម៉ោង ១:៥៨ នាទីរសៀល។ សំណុំរឿង០០២-ឯកសារ **D427/2/12** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នៅម៉ោង ២:០០ រសៀល។ សំណុំរឿង០០២-ឯកសារ **D427/3/12** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នៅម៉ោង ២:០២ នាទីរសៀល។ សំណុំរឿង០០២-ឯកសារ **D427/4/14** សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ នៅម៉ោង ២:១១ នាទីរសៀល។ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ **ខ**។

22. ពាក់ព័ន្ធនឹងការជូនដំណឹងនេះ[20] ស.ព.អ រកឃើញភាសាណែនាំនៃមាត្រា ២.១ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ[21] ដែលចែងនៅក្នុងផ្នែកពាក់ព័ន្ធថា ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក ត្រូវធ្វើឡើងដោយផ្ទាល់ទៅកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះនោះ តាមរយៈមន្ត្រីទទួលបន្ទុកសំណុំរឿង។ តាមរយៈមាត្រានេះ វាហាក់ដូចជាថា ក្រឡាបញ្ជីគឺជាយន្តការផ្លូវការសម្រាប់ការជូនដំណឹងទៅកាន់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង។ ស.ព.អ កត់សម្គាល់ថា ស្របគ្នាទៅនឹងតួនាទីនេះ គឺក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ដែលជាអ្នកបញ្ជូនសារអេឡិចត្រូនិកថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ និង សារអេឡិចត្រូនិកថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ក្នុងនាមអង្គជំនុំជម្រះសាលាដំបូង។

23. បន្ថែមលើនេះ ទោះបីជាមិនមានលក្ខខណ្ឌតម្រូវតាមវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង សម្រាប់ឱ្យអង្គបុរេជំនុំជម្រះ ជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងក៏ដោយ ក៏ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ស្ថិតក្នុងចំណោមអ្នកទាំងឡាយដែលមានឈ្មោះនៅក្នុងបញ្ជីទទួលសារអេឡិចត្រូនិកផ្លូវការថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដែលបានជូនដំណឹងអំពីសេចក្តីពិចារណា ដែលបានផ្ញើចេញដោយមន្ត្រីទទួលបន្ទុកសំណុំរឿង[22] ទំនងជាដូចគ្នាទៅនឹងករណីដែលកើតមាននៅក្នុងសំណុំរឿង ០០២ ដូចបានយោងខាងលើ។

24. ផ្អែកលើការអនុវត្តពីមុនរបស់អង្គជំនុំជម្រះនេះ សេចក្តីណែនាំអនុវត្ត និង ការណ៍ដែលក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង បញ្ជូនព័ត៌មានក្នុងនាមអង្គជំនុំជម្រះសាលាដំបូង ស.ព.អ ស្នើសុំការបំភ្លឺអំពី៖

(i) តើសេចក្តីជូនដំណឹងបន្ថែមអ្វីខ្លះទៀត ដែលអង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមាននៅក្នុងរឿងក្តីនេះ ក្រៅពីសេចក្តីជូនដំណឹងតាមសារអេឡិចត្រូនិកផ្លូវការ ស្តីពីសេចក្តីពិចារណា ដែលបានផ្តល់ទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩?

---

20 ស.ព.អ សួរថាតើការខកខានមិនបានជូនដំណឹងដល់ពួកចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទាំងអស់នៅក្នុងករណីនេះ គឺបណ្តាលមកពីរឿងធម្មតានៃការបំពេញទម្រង់រដ្ឋបាល ដែលបានផ្តល់នូវការចូលមើលសំណុំរឿងបាន។ *សូមមើល* សំណើសុំចូលមើលសំណុំរឿង និងមើល Zyimage ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ **ច**។

21 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨ ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក សេចក្តីណែនាំអនុវត្ត។

22 *សូមមើល* ឧបសម្ព័ន្ធ **ខ**។

## ខ. ការបញ្ជូនសំណុំរឿងនៃរឿងក្ដី ០០៤/២

25. ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានកត់សំគាល់ថា "ការចូលមើលសំណុំរឿងនេះ មិនមែនជាការទទួលសំណុំរឿងជាលក្ខណៈផ្លូវការនោះទេ រហូតដល់ពេលមានការចេញ **សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍ចំពោះដីកាដំណោះស្រាយនេះសិន**"[23]។ ស.ព.អ កត់សំគាល់បន្ថែមថា[24] អង្គជំនុំជម្រះនេះត្រូវបានប្ដឹងនូវសំណុំរឿង០០២ បន្ទាប់ពីមាន*ដំណោះស្រាយលើគ្រប់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដំណោះស្រាយទាំងអស់* មានន័យថា បណ្ដឹងឧទ្ធរណ៍របស់ អៀង សារី បណ្ដឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ បណ្ដឹងឧទ្ធរណ៍របស់ នួន ជា និងបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន។ តាមស្មារតីនេះ ស.ព.អ សូមស្នើការបំភ្លឺពីគោលជំហររបស់អង្គជំនុំជម្រះសាលាដំបូង លើសារសំខាន់នៃការបញ្ជូនសំណុំរឿងនេះទៅអង្គជំនុំជម្រះសាលាដំបូង ដែលអង្គជំនុំជម្រះនេះត្រូវបានប្ដឹងឲ្យទទួលយកនូវសំណុំរឿងនេះដោយអនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុងដោយសារអង្គបុរេជំនុំជម្រះបរាជ័យក្នុងការស្វែងរកសំឡេងគាំទ្រលើសលុបដើម្បីបដិសេធលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ។[25]

26. និយាយឲ្យចំ ស.ព.អ សូមស្នើបញ្ជាក់បំភ្លឺលើបញ្ហាមួយចំនួនដូចខាងក្រោម៖

(ii) តាមគោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងថាតើ សំណុំរឿង ០០៤/២ មិនត្រូវបានប្ដឹងទៅខ្លួននោះទេ រហូតទាល់តែខ្លួនបានទទួលសំណុំរឿងនេះ ទោះបីជាតាមលទ្ធភាពចូលបានតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមប្រព័ន្ធផ្សេងទៀតក៏ដោយ តើមែនឬទេ? ប្រសិនបើចម្លើយទៅនឹងសំណួរនេះជាចម្លើយស្រប

---

[23] សំណុំរឿង ០០១-ឯកសារ **D99/3/5** សេចក្ដីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូងសុំការអនុញ្ញាតពិនិត្យសំណុំរឿង, ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ (សង្កត់ន័យដើម)។ អង្គជំនុំជម្រះសាលាដំបូងទទួលបានការអនុញ្ញាតរួចហើយដើម្បីចូលពិនិត្យសំណុំរឿង ខណៈដែលបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿងនេះ កំពុងតែដំណើរការនៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ចំពោះ ស.ព.អ នេះបង្កប់ន័យថា ការប្ដឹងឲ្យទទួលយកសំណុំរឿងនេះ គឺត្រូវបានកំណត់ដោយការបញ្ចប់ដំណើរការលើបណ្ដឹងឧទ្ធរណ៍នៅមុនពេលសវនាការជំនុំជម្រះ និងមិនមែនផ្អែកលើការបញ្ជូនជាផ្លូវការនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។ *សូមមើលផងដែរ* សំណុំរឿង ០០១- ឯកសារ **E5** សេចក្ដីជូនដំណឹងពីកិច្ចប្រជុំរៀបចំសវនាការ និងដីកាបង្គាប់ឲ្យភាគីដាក់ឯកសារបន្ថែម, ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៨, ERN 00250110-11។ សំណុំរឿង០០១-ឯកសារ **E188** សាលក្រម, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, កថាខណ្ឌ ៣៧។

[24] សំណុំរឿង ០០២-ឯកសារ **E313** សាលក្រមសំណុំរឿង ០០២/០១, ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ ២៣។ សំណុំរឿង ០០២-ឯកសារ **E465** សាលក្រមសំណុំរឿង ០០២/០២, ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨, កថាខណ្ឌ ៣៣។

[25] *សូមមើល* ឯកសារ **D359/24 & D360/33** សេចក្ដីពិចារណា, កថាខណ្ឌ ៦៨៧។

(iii) តើមានភាពខុសគ្នាអ្វីខ្លះរវាងសំណុំរឿងនៅពេលនេះ ទៅនឹងសំណុំរឿង ០០១ និង សំណុំរឿង ០០២ ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ខ្លួនត្រូវបានប្តឹងឲ្យទទួលយកសំណុំរឿងនោះ នៅថ្ងៃអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ? និងជាចុងក្រោយ

(iv) តើវាជាគោលជំហររបស់អង្គជំនុំជម្រះសាលាដំបូងដែលថា ខ្លួនគ្មានសិទ្ធិអំណាច (ជាផ្លូវការ ឬដែលជាប់មកជាមួយ) ដើម្បីបង្គាប់ឲ្យបញ្ជូនសំណុំរឿងនេះ ដើម្បីស្នើទៅអង្គបុរេជំនុំជម្រះឲ្យបញ្ជូនសំណុំរឿងនេះ និង/ឬ ដើម្បីចាត់វិធានការដើម្បីឲ្យរឿងក្តីនេះធ្វើដំណើរការទៅមុខ មែនឬទេ?

## គ. <u>តម្លាភាពនៃដំណើរការរឿងក្តីបច្ចុប្បន្ននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង</u>

27. ដោយសារគ្មានលេខសំណុំរឿងត្រូវបានដាក់ឲ្យ សម្រាប់កិច្ចដំណើរការនីតិវិធីសំណុំរឿង ០០៤/២ នៅចំពោះមុខអង្គជំនុំជុំម្រះសាលាដំបូង ការដាក់ឯកសារនានារហូតមកដល់ពេលនេះ ត្រូវបានបញ្ជូនជាឯកសាររឹងទៅកាន់ផ្នែកគ្រប់គ្រងតុលាការ ដោយមានសំណៅចម្លងជូនទៅគូភាគីនានា ឬត្រឹមតែបានប្រាស្រ័យទំនាក់ទំនងជាមួយគូភាគី តាមរយៈសារអេឡិចត្រូនិកប៉ុណ្ណោះ។ ស.ព.អ ជូនជាយោបល់ថា ការអនុវត្តនេះធ្វើឲ្យមានកង្វះនូវតម្លាភាព ដោយសារតែសាធារណជនកម្ពុជា និងសហគមន៍អន្តរជាតិ មិនបានជ្រួតជ្រាបអំពីដំណើរការដែលកំពុងតែបន្តនេះទេ។

28. ស.ព.អ សន្និដ្ឋានថា ដោយហេតុថា កិច្ចស៊ើបសួរជាសម្ងាត់ក៏បានបញ្ចប់ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក៏បានចេញជាសាធារណរួចហើយដែរ នៅឡើយតែគោលការណ៍នៃតម្លាភាព និងសាធារណភាពដែលត្រូវអនុវត្ត ដូចបានទទួលស្គាល់ដោយមាត្រា ១២(២) នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ២១(១) នៃវិធានផ្ទៃក្នុង ដើម្បីលើកកម្ពស់ភាពជឿជាក់ទៅលើដំណើរការរបស់តុលាការ។ អាស្រ័យដោយសារសំខាន់នៃបញ្ហានានាដែលពាក់ព័ន្ធ និងផលប្រយោជន៍ពេញសិទ្ធិរបស់សាធារណជន អំពីការរីកចម្រើននៃរឿងក្តីទាំងនេះ ស.ព.អ នៅតែប្រកាន់ជំហររបស់ខ្លួនស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ផ្តល់ទៅ CMS នូវលេខសំណុំរឿងមួយសម្រាប់រឿងក្តីនេះ[26] ដើម្បីឲ្យការដាក់ឯកសារនានាអាចត្រូវបានជូនដំណឹងជាផ្លូវការទៅដល់សាធារណជន ឬបើតាមជម្រើសផ្សេងពីនេះ សូមស្នើថា សារណាសន្និដ្ឋានរបស់ ស.ព.អ ទាំង

[26] សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើដល់អង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការដើម្បីទទួលបានលទ្ធភាពពិនិត្យដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងសំណុំរឿងនៃសំណុំរឿង ០០៤/០២ (អោ អាន), ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០, កថាខណ្ឌ៣០(គ)។

អស់ដែលបានដាក់មកទល់ពេលនេះ ធ្វើឲ្យទៅជាសាធារណៈ ដែលអាចរកបានតាមរយៈគេហទំព័ររបស់ អ.វ.ត.ក។

## V. ឧបាស្រ័យដែលស្នើឡើង

29. អាស្រ័យមូលហេតុដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិសូមស្នើឲ្យមានការបំភ្លឺលើសារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូង ដូចមានចែងកំណត់ក្នុងចំណុច (i)-(iv) ក្នុងកថាខណ្ឌ ២៤ និង ២៦ ខាងលើ និងសូមស្នើថា ការដាក់ឯកសាររបស់ ស.ព.អ ជូនទៅអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០៤/២ ធ្វើឲ្យរកបានជាសាធារណៈ៕

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ | លោកស្រី **Brenda J. HOLLIS**<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |